**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ: ០៦ សសរ**

# សេចក្តីសម្រេច

## ស្តីពីការបង្កើតក្រុមការងារអន្តរក្រសួង សម្រាប់សម្របសម្រួលការប្រមូលចងក្រងព័ត៌មាន ពាក់ព័ន្ធលើ គំរោងអភិវឌ្ឍន៍បឹងទន្លេសាប

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ១២៩៨ / ១០៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពី ការបង្កើតក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញ ព្រះរាជក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ សមាសភាព រចនាសម្ព័ន្ធ តួនាទីភារកិច្ច និងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៧០ ចុះថ្ងៃទី១០ ខែ មេសា ឆ្នាំ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងជម្រកជីវមណ្ឌលបឹងទន្លេសាប
- បានឃើញ អនុក្រឹត្យលេខ ៩៤ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានជម្រកជីវមណ្ឌលបឹងទន្លេសាប
- យោងលិខិតលេខ ៧៣៥ សជណ.កស របស់ទីស្តីការគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៥

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៤១ មហាវិថីសហព័ន្ធរុស្ស៊ី ទូរសារ : ០២៣ ៨៨០ ៦២៤ ទូរស័ព្ទ : ០១១ ៩៦០ ១៩៩ / ០១២ ៨៨១ ៩៦៦

# ស ម្រេ ច

**ប្រការ១.-**

បង្កើតក្រុមការងារ សម្រាប់សម្របសម្រួលការប្រមូលចងក្រងព័ត៌មានពាក់ព័ន្ធលើ គំរោងអភិវឌ្ឍន៍បឹងទន្លេសាប ដែលមានសមាសភាព ដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **នូច ភានុន** | អគ្គលេខាធិការ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | ប្រធាន |
| ២-ឯកឧត្តម | **គល់ ទឡ្ហនា** | អគ្គលេខាធិការរង នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | អនុប្រធាន |
| ៣- លោក | **ចាន់ ដារ៉ុង** | អគ្គនាយករងបច្ចេកទេស នៃក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៤- លោក | **ចេង ចំនួនពណ្ណារ៉ា** | ប្រធានការិយាល័យផែនការ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ | លេខាធិការ |
| ៥- ឯកឧត្តម | **ម្លូង សារេត** | អគ្គលេខាធិការរង នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ | សមាជិក |
| ៦-លោកជំទាវ | **ជូ ប៊ុនអេង** | អគ្គនាយកអភិវឌ្ឍន៍សង្គម នៃក្រសួងកិច្ចការនារី | សមាជិក |
| ៧-លោក | **ហង្ស ប៊ុណ្ណាក់** | អគ្គនាយករង នៃអគ្គនាយកដ្ឋាន នៃក្រសួងរៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ៨-លោក | **គីកវ៉េត សំរេច** | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៩-លោក | **ឈា ប៊ុនរិទ្ធ** | អនុប្រធាននាយកដ្ឋានផែនការ និងសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងធនធានទឹក និង ឧតុនិយម | សមាជិក |
| ១០-លោក | **នៅ ចោនន់** | អនុប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | សមាជិក |
| ១១-លោក | **នី គីមសាន** | ប្រធានការិយាល័យស្រាវជ្រាវបច្ចេកទេស នៃក្រសួងមហាផ្ទៃ | សមាជិក |
| ១២-លោកស្រី | **គាំង ឃីម** | អនុប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| ១៣-លោក | **ហាក់ ប៊ុណ្ណារិទ្ធ** | អនុប្រធានការិយាល័យ ADB នៃនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

**ប្រការ២.-**

តួនាទី និង ភារកិច្ច

ប្រធាន

- ទទួលខុសត្រូវជាទូទៅលើការងារ របស់ក្រុមការងារ
- ធ្វើជាអធិបតីភាពក្នុងអង្គប្រជុំរបស់ក្រុមការងារ ដឹកនាំពិភាក្សា និង ប្តូកសរុបមតិសម្រេចរបស់អង្គប្រជុំ
- កោះប្រជុំសាមញ្ញ ឬ ក្នុងករណីចាំបាច់ប្រជុំវិសាមញ្ញ នៃអង្គប្រជុំរបស់ក្រុមការងារ
- ទទួលបន្ទុកទំនាក់ទំនងជាមួយភាគីបរទេស ដែលពាក់ព័ន្ធក្នុងក្រុមការងារ ក្នុងគំរោងអភិវឌ្ឍន៍បឹងទន្លេសាប
- ចុះហត្ថលេខាលើកំណត់ហេតុ និងលើសេចក្តីជូនដំណឹងនៃអង្គប្រជុំ ។

អនុប្រធាន

- ត្រូវបំពេញរាល់កិច្ចការ ដែលប្រធានប្រគល់អោយ
- ទទួលខុសត្រូវជាទូទៅលើការងារ របស់ក្រុមការងារ ក្នុងករណីប្រធានអវត្តមាន
- ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារជាប្រចាំ ។

លេខាធិការ

- រៀបចំកម្មវិធីរបស់ក្រុមការងារ និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗ សម្រាប់អង្គប្រជុំ
- រៀបចំកំណត់ហេតុ សេចក្តីជូនដំណឹងអង្គប្រជុំ ដើម្បីដាក់ជូនប្រធានចុះហត្ថលេខា
- រៀបចំរបាយការណ៍ ប្រចាំឆមាស ឬប្រចាំឆ្នាំ
- បំពេញការងារផ្សេងៗទៀត ដែលប្រធាន និងអនុប្រធាន ប្រគល់អោយ ។

សមាជិក

- សមាជិកទាំងអស់ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន
- តំណាងក្រសួងនិមួយៗ ត្រូវស្រាវជ្រាវ និងផ្តល់រាល់ឯកសារសង្ខេបដែលក្រសួង-ស្ថាប័ន កំពុង និងបន្តអនុវត្តពាក់ព័ន្ធលើគំរោងអភិវឌ្ឍន៍បឹងទន្លេសាប ។

**ប្រការ៣.-**

- ក្រុមការងារនេះ ត្រូវរៀបចំប្រជុំសាមញ្ញយ៉ាងតិច០៦ខែម្តង និងប្រជុំវិសាមញ្ញតាមការចាំបាច់ ។

**ប្រការ៤.-**

ក្រុមការងារនេះត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានទីតាំងនៅក្នុងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យ កសិកម្ម និង ជនបទ ក្រោមការគ្រប់គ្រងណែនាំរបស់ឯកឧត្តមប្រធានក្រុមការងារ ដោយមានមន្ត្រីរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មួយចំនួនជាជំនួយការ តាមការចាំបាច់ ។

**ប្រការ៥.-**

ក្រុមការងារនេះ ត្រូវធ្វើការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន និងអង្គការពាក់ព័ន្ធនានាលើការប្រមូលចងក្រងព័ត៌មានពាក់ព័ន្ធសម្រាប់ធ្វើការតាមដានបូកសរុប និងវាយតម្លៃ ក្នុងទិសដៅជួយដល់ការអនុវត្ត កម្មវិធីអភិវឌ្ឍន៍បឹងទន្លេសាបមានភាពរលូន និងមានប្រសិទ្ធភាព និង រាយការណ៍ជូនប្រមុខរដ្ឋាភិបាល ដើម្បីជ្រាប និងផ្តល់ការណែនាំ។

**ប្រការ៦.-**

រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ កុម្ភៈ ឆ្នាំ ២០០៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**<u>ចំលងជូនៈ</u>**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ប្រចាំកម្ពុជា
- ដូចក្នុងប្រការ៦
- ឯកសារ-កាលប្បវត្តិ